**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៩៥ ........សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឲ្យដំណើរការការិយាល័យគយនិងរដ្ឋាករ ប្រចាំសន្និធិគយបណ្តោះអាសន្នក្រុមហ៊ុន ឆាយដា ឡូយីស្ទីក ខូ អិលធីឌី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសន្និធិគយបណ្តោះអាសន្ន
- យោងប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងកិច្ចសន្យាស្តីពីការបង្កើតនិងធ្វើអាជីវកម្មសន្និធិគយបណ្តោះអាសន្នរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងក្រុមហ៊ុន ឆាយ ដា ឡូយីស្ទីក ខូ អិលធីឌី (Chay Da Logistics Co., Ltd.) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**សម្រេច**

**ប្រការ ១ .-**

បង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគយនិងរដ្ឋាករប្រចាំសន្និធិគយបណ្តោះអាសន្នក្រុមហ៊ុនឆាយដា ឡូយីស្ទីក ខូ អិលធីឌី ហៅកាត់ថាការិយាល័យគយនិងរដ្ឋាករផែស្ងួតឆាយដា ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់សាខាគយនិងរដ្ឋាករផែស្ងួត នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ២ .-**

ការិយាល័យគយនិងរដ្ឋាករផែស្ងួតឆាយដាដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣ .-**

ការិយាល័យគយនិងរដ្ឋាករផែស្ងួតឆាយដាមានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញក្នុងទីតាំងសន្និធិគយបណ្តោះអាសន្នរបស់ក្រុមហ៊ុន ឆាយដា ឡូយីស្ទីក ខូ អិលធីឌី លើទំនិញនាំចេញនាំចូលគ្រប់ប្រភេទ លើកលែងតែមានការកំណត់ដោយឡែកពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមបទប្បញ្ញត្តិជាធរមាន
- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យលើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញនាំចូល នាំចេញ ដែលស្ថិតនៅក្នុងសន្និធិគយបណ្តោះអាសន្នរបស់ក្រុមហ៊ុន ឆាយដា ឡូយីស្ទីក ខូ អិលធីឌី លើទំនិញដូចចែងខាងលើ
- ត្រួតពិនិត្យ និងប្រមូលពន្ធអាករនិងចំណូលផ្សេងទៀតលើទំនិញនាំចូលនាំចេញដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីសន្និធិគយបណ្តោះអាសន្នក្រោយពីការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបទប្បញ្ញត្តិជាធរមាន
- បំពេញភារកិច្ចស្រាវជ្រាវ និងបង្ក្រាបបទល្មើសគយក្នុងវង់អំណាចគយជុំវិញសន្និធិគយបណ្តោះអាសន្ននេះតាមបញ្ញត្តិចំណុច ខ កថាខណ្ឌទី៣ មាត្រា៤ នៃច្បាប់ស្តីពីគយ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ .**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ